# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១២៩៩/១៥

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់ទតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ទតព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់ទតព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រី និង អតិទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្រប តាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

## ស្តីពីចំណូល-ចំណាយ នៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតសំរាប់ឆ្នាំ២០០០ ឲ្យប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសំរេចនូវអំណោយមូលនិធិឧបត្ថម្ភ និង ធនធានបានមកពីការខ្ចី ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន២.៣៥៥.០០០ លដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលជាប្រចាំ ------------------------------------------------ ១.៤៨៥.០០០ លានរៀល
- ចំណូលជាមូលធន ---------------------------------------------- ៨៧០.០០០ លានរៀល
    + ចំណូលជាមូលធនក្នុងប្រទេស --------------------------------- ២០.០០០ លានរៀល
    + ចំណូលជាមូលធនក្រៅប្រទេស --------------------------------- ៨៥០.០០០ លានរៀល

**មាត្រា ២.-** ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ត្រូវបានកំណត់ស្មើនឹង ------------------------------ ២.៣៥៥.០០០ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយជាប្រចាំ ------------------------------------------------ ១.៣១៥.០០០ លានរៀល

- ចំណាយជាមូលធន ---------------------------------------------------- ១.០៥០.០០០ លានរៀល
  - + ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស ---------------- ៣២០.០០០ លានរៀល
    - ★ ដោយមូលនិធិថវិកា ------------------------------------------ ១៧០.០០០ លានរៀល
    - ★ ដោយមូលនិធិក្រៅប្រទេស ដែលអ្នកផ្តល់អំណោយបានយល់ព្រមជាមុន ------------------------------------------------------------ ១៥០.០០០ លានរៀល
  - + ចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលអនុវត្តក្រៅ រតនាគារជាតិ៧០០.០០០ លា
  - + ចំណាយរំលស់បំណុល ----------------------------------------- ២០.០០០ លានរៀល

**មាត្រា ៣.-** ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សំរាប់ចំណាយជាប្រចាំរបស់រដ្ឋសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ត្រូវបានកំណត់ស្មើនឹង ---------------------------------- ១.៣១៥.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែល នីមួយៗ និង ទៅតាមប្រភេទនៃថវិកាដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយ ច្បាប់នេះ ។

**មាត្រា ៤.-** ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដល់ ២០០២ ត្រូវបានកំណត់ស្មើនឹង ------------------------------------------------ ៤.១៣០.០៧៩ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែល នីមួយៗ តាមជំពូក និងតាមឆ្នាំដូចមានចែងក្នុងតារាង "គ" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា ៥.-** ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សំរាប់ចំណាយជា មូលធននៃថវិការដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ត្រូវបានកំណត់ដូចតទៅ ÷

- ឥណទានភ្ជាប់សន្យា ------------------------------------------ ១.៣៥០.០០០ លានរៀល
- ឥណទានទូទាត់ ----------------------------------------------- ១.០៥០.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកដូចតទៅ ÷

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ÷

- ឥណទានភ្ជាប់សន្យា ------------------------------------------ ៣២០.០០០ លានរៀល
- ឥណទានទូទាត់ ----------------------------------------------- ៣២០.០០០ លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ÷

- ឥណទានភ្ជាប់សន្យា ------------------------------------------ ១.០០០.០០០ លានរៀល
- ឥណទានទូទាត់ ----------------------------------------------- ៧០០.០០០ លានរៀល

ឆ- ការរំលស់បំណុលក្រៅប្រទេស ÷

- ឥណទានពហុភាគី ---------------------------------------------------២០.០០០ លានរៀល
- ឥណទានទ្វេភាគី ----------------------------------------------------២០.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រយោជន៍ប្រតិបត្តិ នីមួយៗ និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

## ជំពូកទី ២

## បទប្បញ្ញត្តិ

## ស្ដីពីលំនឹងសាច់ប្រាក់នៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ៦.-** តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលបានសរុបចេញពីតារាង "ក" ស្ដីពីចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង "ខ" ស្ដីពីចំណាយថវិកាទូទៅរបស់រដ្ឋ ត្រូវបាន បង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដូចតទៅ ÷

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+)<br>ឱនភាព (-) |
|---|---|---|
| I. ចំណូលក្នុងប្រទេស | ១.៥០៥.០០០ | |
| ១- ចំណូលជាប្រចាំ | ១.៤៨៥.០០០ | |
| ២- ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ២០.០០០ | |
| II. សរុបចំណាយថវិកា (១) | ២.៣៣៥.០០០ | |
| ១- ចំណាយជាប្រចាំ | ១.៣១៥.០០០ | |
| ២- ចំណាយជាមូលធន (១) | ១.០២០.០០០ | |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៣២០.០០០ | |
| +ដោយមូលនិធិថវិកា | ១៧០.០០០ | |
| *គំរោងវិនិយោគ (សាងសង់-ទិញសំភារៈ) | ៧០.០០០ | |
| *បរិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ១០០.០០០ | |
| +ដោយមូលនិធិក្រៅប្រទេសដែលមានការបរព្រមជា | | |

| | | |
|---|---|---|
| មុនពីអ្នកផ្តល់ជំនួយ | ១៥០.០០០ | |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៧០០.០០០ | |
| **អតិរេកនៃថវិកាជាប្រចាំ** | | +<u>១៧០.០០០</u> |
| **ឱនភាពសរុបនៃថវិកាទូទៅ** | | <u>-៨៣០.០០០</u> |
| **III. ហិរញ្ញប្បទាននៃឱនភាព** | | +៨៣០.០០០ |
| ១- ហិរញ្ញប្បទានក្រៅប្រទេស | | +៨៥០.០០០ |
| - ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុន ពីអ្នកផ្តល់ជំនួយ | | +១៥០.០០០ |
| - ជំនួយគំរោងការ | | +៧០០.០០០ |
| ២- ការរំលស់បំណុល | | -២០.០០០ |
| ៣- ហិរញ្ញប្បទានធនាគារ | | 0 |

(១) មិនគិតការរំលស់បំណុល (២០.០០០លានរៀល) ដែលមានកំណត់នៅក្នុងសារបញ្ជី III "ហិរញ្ញប្បទាននៃឱនភាព"

## ជំពូកទី ៣

## បទប្បញ្ញត្តិ ស្តីពីចំណូលថវិកា

**មាត្រា ៧.-** ក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធទៅនឹងការលក់ ការជួលចលនវត្ថុ ឬអចលនវត្ថុ ដែលជាទ្រព្យ-សម្បត្តិរបស់រដ្ឋ ឬក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធទៅនឹងសេវាបង់ថ្លៃរបស់រដ្ឋ ពុំមានចែងអំពីការពិន័យទេនោះ មុនឈានដល់ការរំលាយចោលកិច្ចសន្យា ដូចមានចែងក្នុងមាត្រា១១ នៃច្បាប់នេះ ត្រូវអនុវត្តការពិន័យពីរ (២) ភាគរយក្នុងមួយខែលើចំនួនទឹកប្រាក់ ដែលមិនទាន់បានទូទាត់ ជូនរដ្ឋ ចាប់ពីហុកសិប (៦០) ថ្ងៃក្រោយការកំណត់តទៅ ។

បទប្បញ្ញត្តិនេះមិនអនុវត្តចំពោះកិច្ចសន្យាទាំងឡាយណា ដែលមានចែងអំពីការពិន័យ រួចហើយនោះទេ ។

## ជំពូកទី៤

## បទប្បញ្ញត្តិ ស្តីពីការកែប្រែមាត្រា ៣ មាត្រា ១៧ និងមាត្រា ៥៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

**មាត្រា ៨.-** មាត្រា ៣ មាត្រា ១៧ និងមាត្រា ៥៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានកែប្រែដោយបទប្បញ្ញត្តិដូចតទៅ :

**មាត្រា ៣ (ថ្មី) :**

គណនីថវិការួមមានថវិកាទូទៅរបស់រដ្ឋ *ថវិកាឧបសម្ព័ន្ធ* *ថវិកានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល* និងគណនីពិសេសនៃរតនាគារ ។ គណនីថវិកាផ្សេងៗទៀត អាចត្រូវបង្កើតក្នុងច្បាប់ហិរញ្ញវត្ថុ ។

ថវិកាឧបសម្ព័ន្ធ ត្រូវអនុវត្តចំពោះអង្គភាពរដ្ឋ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម តែពុំមែនជានីតិបុគ្គលទេ ។ ថវិកាឧបសម្ព័ន្ធត្រូវបានបង្កើត ឬលុបចោលដោយច្បាប់ហិរញ្ញវត្ថុ ។ កិច្ចប្រតិបត្តិការនៃថវិកាឧបសម្ព័ន្ធ ត្រូវប្រព្រឹត្តទៅក្នុងលក្ខខណ្ឌ និងតាមវិធានដូចគ្នានៃកិច្ចប្រតិបត្តិការរបស់រដ្ឋដែរ ។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានថវិកាស្វយ័ត ។ ប្រភពធនធានជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរួមមានចំណូលផ្ទាល់ និងជាប្រចាំរបស់ មានការឧបត្ថម្ភ តុល្យភាពដោយថវិកាទូទៅរបស់រដ្ឋ ។ រីឯចំណាយជាប្រចាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចចំណាយជាប្រចាំរបស់រដ្ឋដែរ ។

ការរៀបចំនិងការប្រព្រឹត្តិទៅនៃថវិកាឧបសម្ព័ន្ធដែលជាអង្គភាពរដ្ឋ ឬជាគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧ (ថ្មី) :**

ឥណទានថវិកាដែលបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុ ត្រូវបានបែងចែកនៅផ្នែកក្នុង ប្រភេទនីមួយៗ ជាជំពូក ប្រការ កថាខណ្ឌ និងអនុកថាខណ្ឌទៅតាមលក្ខណៈ ឬគោលដៅនៃឥណទានថវិកា។ ឥណទានទាំងនេះ ក៏អាចធ្វើជាកម្មវត្ថុនៃការប្រមូលផ្តុំតាមផ្នែកដែរ ។

ចំណាត់ថ្នាក់ចំណាយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណាយជាប្រចាំនៃប្រភេទ ២ : *-ការប្រាក់នៃការខ្ចី* -និងប្រភេទ ៥ : *-ចំណាយ ផ្សេងៗ និងចំណាយមិនបានគ្រោងទុក* ព្រមទាំងចំណាយជាមូលធននៃការសងបំណុលមិនត្រូវបានបែងចែកទៅឲ្យក្រសួងណា ឬស្ថាប័នសាធារណៈប្រហាក់ប្រហែលណាមួយឡើយ ។

ប្រភេទ ៥ នៃចំណាយជាប្រចាំ គឺមួយផ្នែកសំរាប់ចំណាយផ្សេងៗ ចំណាយបេសកកម្ម ឬចំណាយបង្វិលសងវិញ ព្រមទាំងឥណទានត្រៀមបំរុង និងមួយផ្នែកទៀតសំរាប់ចំណាយមិនបានគ្រោងទុក ។

ឥណទានត្រៀមបំរុងត្រូវបានអនុញ្ញាតសំរាប់ការចំណាយទាំងឡាយណា ដែលការបែងចែកមិនអាចត្រូវបានកំណត់ជាក់លាក់នៅពេល ដែលឥណទាននោះត្រូវបានអនុម័ត ។ ការបែងចែក

ឥណទានត្រៀមបម្រុងទាំងនេះ តាមក្រសួងនីមួយៗនិងស្ថាប័នសាធារណៈប្រហាក់ប្រហែលនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចី ចំណាយផ្សេងៗ ចំណាយសំណង និងចំណាយបង្វិលសងវិញព្រមទាំងចំណាយសង បំណុល ។

**មាត្រា ៤៨ (ថ្មី) :**

ការអនុវត្តន៍កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋនិងគណនីពិសេសរបស់រតនាគារ ជាភារកិច្ច របស់អាណាប័ក និងគណនេយ្យករសាធារណៈ ។ អាណាប័ក និងគណនេយ្យករ សាធារណៈ មានមុខងារវិសមិតភាពពីគ្នា ។

រដ្ឋមន្ត្រីនិងប្រធានស្ថាប័នសាធារណៈប្រហាក់ប្រហែល ជាអាណាប័កដើមខ្សែនៃថវិការដ្ឋចំពោះផ្នែកចំណូលដែលបានមកពីផ្នែករបស់ខ្លួន និងចំពោះផ្នែកចំណាយនៅ រដ្ឋបាលកណ្តាល និងនៅអង្គភាពខាងក្រៅដែលស្ថិតក្រោមឱវាទនៅតាមខេត្ត-ក្រុង ។ រដ្ឋមន្ត្រី និងប្រធានស្ថាប័នសាធារណៈប្រហាក់ប្រហែលជាអ្នកបញ្ជាចំណូល-ចំណាយថវិកា តាមផ្នែករៀងៗខ្លួន ។

រដ្ឋមន្ត្រីនិងប្រធានស្ថាប័នសាធារណៈប្រហាក់ប្រហែលជាអាណាប័កដើមខ្សែ នៃថវិការបស់ខ្លួន ប្រគល់សិទ្ធិជូនអភិបាលខេត្ត-ក្រុង ជាអាណាប័កផ្ទេរសិទ្ធិសំរាប់កិច្ច ប្រតិបត្តិការហិរញ្ញវត្ថុថវិការដ្ឋក្នុងមណ្ឌលដែនដីរបស់ខ្លួន ។

រដ្ឋមន្ត្រីនិងប្រធានស្ថាប័នសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួនអាចប្រគល់សិទ្ធិជូនប្រធានមន្ទីរជំនាញខេត្ត-ក្រុង ជាអាណាប័កផ្ទេរសិទ្ធិ សំរាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ថវិការដ្ឋនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បទបញ្ជានៃគណនេយ្យសាធារណៈ ជ្រើសតាំងប្រភេទមន្ត្រីរាជការ ដែលអាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិ ឬជំនួសខ្លួនក្នុងករណីដែលអាណាប័កដើមខ្សែអវត្តមាន ឬមានធុរៈ ។ ការផ្ទេរសិទ្ធិ ឬការចុះហត្ថលេខា ត្រូវធ្វើឡើងដោយប្រកាសបន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិ

## ស្តីពីការទទួលខុសត្រូវ នៃអ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ

**មាត្រា៩.** ហាមឃាត់ដាច់ខាតមិនឲ្យប្រធានស្ថាប័នរដ្ឋបាលនិងអាណាប័កដើមខ្សែ ព្រមទាំងអាណាប័កផ្ទេរ ចាត់ចែងការចំណាយដែលនាំឲ្យកើនចំណាយលើឥណទានថវិកាទូទៅរបស់រដ្ឋ ដែលពុំមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ ឬច្បាប់ អនុក្រឹត្យ និងបទបញ្ជា ដែលមានពីមុនកិច្ចសន្យាចំណាយ ។

**មាត្រា១០.-** ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា១៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ត្រូវបានចាត់ទុកជា កំហុសនៃការគ្រប់គ្រង ដែលបានប្រព្រឹត្តចំពោះរដ្ឋ ដូចជា :

- រាល់អំពើដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដូចមានចែងក្នុង ច្បាប់នេះ ។
- រាល់អំពើដែលបានចុះកិច្ចសន្យាចំណាយលើសឥណទានថវិកា ដែលបានអនុម័តដោយរដ្ឋសភាលើកលែងតែឥណទានដែលបានគ្រោងទុកសំរាប់បើកបៀវត្ស និងប្រាក់វិភាគទានសង្គម សេវាបំណុលនិងសងប្រាក់ខ្ចី ដែលបានយល់ព្រមដោយរដ្ឋសភា ព្រមទាំងការបង់វិភាគទានចំពោះអង្គការអន្តរជាតិនានា ។
- រាល់អំពើដែលជាកម្មវត្ថុសំរាប់បង្កើនទឹកប្រាក់ឥណទានថវិកា ដែលបានទទួលការអនុញ្ញាតពីរដ្ឋសភាដោយធនធានពិសេស ក្រៅពីករណីដែលបានកំណត់ដោយច្បាប់ និងបទបញ្ជាជាធរមាន និងដោយអនុសញ្ញាអន្តរជាតិ ដែលរដ្ឋសភាបានអនុម័ត យល់ព្រម ។
- រាល់កំហុសធ្ងន់ធ្ងរដែលនាំឲ្យមានការខាតបង់ប្រាក់កាស ដែលហិរញ្ញវត្ថុសាធារណៈទទួលរ៉ាប់រង ។
- រាល់សកម្មភាពគ្រប់ប្រភេទដែលប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ និងបទបញ្ជាដែលអនុវត្តចំពោះចំណូល និងចំណាយរបស់រដ្ឋ ។

**មាត្រា១១.-** ដោយអនុលោមទៅតាមមាត្រា៩ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ "កិច្ចប្រតិបត្តិការជាលក្ខណៈពាណិជ្ជកម្ម ដែលទទួលធ្វើដោយអង្គភាពរបស់រដ្ឋដោយផ្ទាល់ ត្រូវបានដឹកនាំ តាមទំលាប់ប្រើប្រាស់ជាធរមានក្នុងវិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម ក្រោមការត្រួតពិនិត្យ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ" ។

ជាពិសេសកិច្ចសន្យាស្តីពីសម្បទានលើធនធាននៃទ្រព្យសម្បត្តិរដ្ឋ ឬការលក់ផលិតផលនៃអាជីវកម្ម ត្រូវបានសំរេចដោយផ្អែកទៅតាមល័ក្ខខ័ណ្ឌ និងបែបបទជាធរមាននៅលើ ទីផ្សារអន្តរជាតិ និងគ្រប់ទៅតាមតំលៃជាក់ស្តែងនៃទីផ្សារ ។

ត្រូវរំលាយចោលនូវរាល់កិច្ចសន្យាដែលទាក់ទងទៅនឹងការលក់ ឬការជួលចលនវត្ថុ ឬ អចលនវត្ថុ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងរាល់ការចាត់ចែងប្រើប្រាស់ទ្រព្យសម្បត្តិទាំងឡាយនោះ ក្នុងករណីដែលប្រធានស្ថាប័នធ្វើលិខិតវាំហើយ តែអ្នកទិញ អ្នកជួល ឬអ្នកទទួលផលប្រយោជន៍ នៅតែមិនគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ដូចជាការបំពាក់ថ្លៃលក់ ឬការបង់ថ្លៃឈ្នួលមិនបានទាន់ពេលវេលា ។

ត្រូវរំលាយចោលនូវកិច្ចសន្យាដូចគ្នានេះដែរ ចំពោះសេវាបង់ថ្លៃរបស់រដ្ឋដែលបានចុះកិច្ចសន្យារវាងសេវាសាធារណៈនិងឯកជន ឬអង្គការពពិយ ក្នុងករណីដែលកិច្ចសន្យាទាំងឡាយនោះ ធ្វើឲ្យប៉ះពាល់ដល់ចំណូលរបស់រដ្ឋ ឬ អ្នកទទួលផលប្រយោជន៍មិនបានគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ។

មាត្រា១២.- ត្រូវបង់ចូលថវិកាមូលដ្ឋានរបស់រដ្ឋ នូវចំណូលទាំងអស់ដែលបានមកពីកិច្ចប្រតិបត្តិការដូចមានបញ្ជាក់ នៅក្នុងមាត្រា១១ នៃច្បាប់នេះ ដោយគ្មានកាត់កងនូវចំណូលទាំងនោះ សំរាប់ទូទាត់សោហ៊ុយចំណាយនៃកិច្ចប្រតិបត្តិការនោះឡើយ ។

មាត្រា១៣.- ប្រធានស្ថាប័ន អាណាប័កដើមខ្សែ និងអាណាប័កតាមការប្រទានសិទ្ធិ ព្រមទាំងមន្ត្រីរាជការ និងភ្នាក់ងាររដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់លើការប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកនេះ ។

ប្រធានស្ថាប័នត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តន៍ចំណូល ចំណាយថវិការបស់ខ្លួន និងធ្វើរបាយការណ៍ស្តីពីសភាពការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដែល បានប្រគល់ឲ្យខ្លួនកាន់កាប់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច តាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបង្ហាញនូវលទ្ធផលដែលសំរេចបាន និងការខ្វះខាតដែលបានកត់សំគាល់ ព្រមទាំងដោយប្រៀបធៀបទៅនឹងគំរោង និងគោលដៅព្រមទាំងលើកវិធានការកែលំអនូវការខ្វះខាតទាំងនោះ ។

## ជំពូកទី ៦

## បទប្បញ្ញត្តិ

## ស្តីពីការខ្ចី និង ការធានារបស់រដ្ឋ

**មាត្រា១៤.-** ចំនួនទឹកប្រាក់ជាអតិបរមាដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឲ្យខ្ចីមានកំរិតរហូតដល់ ២០០.០០០.០០០ S.D.R (ពីររយលាន អេសឌីអ៊ែរ) សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០។

នៅក្នុងល័ក្ខខ័ណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬ លើការធានារបស់រដ្ឋ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទាន ដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិ នៃ កម្ពុជា ត្រូវបានទទួលការអនុញ្ញាតឲ្យលក់ប័ណ្ណរតនាគារក្នុងកំរិតទឹកប្រាក់ ចំនួន ៥០.០០០.០០០.០០០រ (ហាសិបពាន់លានរៀល) ដើម្បីបំបាត់នូវឱនភាពថវិកា ឬសំរាប់ដោះស្រាយតំរូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ ល័ក្ខខ័ណ្ឌនៃការលក់ប័ណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

រាល់ការខ្ចីនិងការធានារបស់រដ្ឋតាមល័ក្ខខ័ណ្ឌពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០០០ ត្រូវអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភាតាមគំរោងនីមួយៗ ។

**មាត្រា១៥.-** មិនអនុញ្ញាតឲ្យក្រសួង ឬ ស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយមានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬ ចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬ ការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័ន សាធារណៈ ឬឯកជនឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និង ល័ក្ខខ័ណ្ឌទាំងឡាយ ដែលច្បាប់នេះបានកំណត់នោះទេ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តបទប្បញ្ញត្តិ នៃជំពូកនេះ ជូនរដ្ឋសភា និងព្រឹទ្ធសភារៀងរាល់ ៦ខែម្តង ។

## ជំពូកទី ៧

## បទប្បញ្ញត្តិ

## ស្ដីពីថវិការបស់ខេត្ត-ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

មាត្រា១៦.- ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ កញ្ចប់ថវិការួមនៃថវិការបស់ខេត្ត-ក្រុង សំរាប់ការ គ្រប់គ្រងឆ្នាំ ២០០០ ត្រូវបានកំណត់ជាចំណូល និងចំណាយចំនួន ------------------------ ៤៥.០០០លានរៀល ដែលបានមកពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធផ្ទាល់របស់ខេត្ត-ក្រុង ចំនួន ---------------------------------------------------------------------------- ២៥.០០០លានរៀល

និងទទួលការឧបត្ថម្ភពីថវិការដ្ឋ ចំនួន ---------------------------------------- ២០.០០០លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមខេត្ត-ក្រុងនីមួយៗ ក៏ដូចជាបែងចែកឥណទាន នៅផ្ទៃក្នុងថវិកានេះ ជាជំពូក ប្រការ កថាខណ្ឌ និងអនុកថាខណ្ឌ ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

មាត្រា១៧.- បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៨.- ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

★★★

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការគ្រប់គ្រងឆ្នាំ ២០០០
## តារាង "ក"
## ចំណូលថវិកាចរន្តរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និងអនុកថាខ័ណ្ឌ

ឯកតា : លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | អនុកថាខ័ណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០០ | លំអៀង ខ្វះ(-) | លំអៀង លើស(+) |
|---|---|---|---|---|---|---|---|---|
| | | | | សរុបរួមកិច្ចប្រតិបត្តិការថវិកា | ១.៥៩៥.០០០ | ២.៣៥៥.០០០ | | +៧៦០.០០០ |
| | | | | ក្នុងនោះចំណូលក្នុងស្រុក | ១.២៤៥.០០០ | ១.៥០៥.០០០ | | +២៦០.០០០ |
| | | | | សរុបចំណូលជាប្រចាំ | ១.២២០.០០០ | ១.៤៨៥.០០០ | | +២៦៥.០០០ |
| | | | | ប្រភេទទី ១ : ពន្ធ និង អាករ | ៨៥៣.២៨០ | ១.០៦៥.០០០ | | +២១១.៧២០ |
| ១០ | | | | ជំពូក១០ : ពន្ធលើផលទុនប្រាក់ចំណេញ និង កំរៃទុន | ៨១.០០០ | ១០៣.៦០០ | | +២២.៦០០ |
| | ០១ | | | ពន្ធលើប្រាក់បៀវត្ស | ១៥.០០០ | ១៥.០០០ | | |
| | ០២ | | | ពន្ធលើប្រាក់ចំណេញ | ៦០.០០០ | ៨១.៦០០ | | +២១.៦០០ |
| | | ០១ | | សហគ្រាសសាធារណៈ | ៨.០០០ | ៨.០០០ | | |
| | | | ០១ | សហគ្រាសមជ្ឈិម | ៨.០០០ | ៨.០០០ | | |
| | | | ០២ | សហគ្រាសខេត្តនានា | | | | |
| | | ០២ | | សហគ្រាសឯកជន | ៥២.០០០ | ៧៣.៦០០ | | +២១.៦០០ |
| | ០៥ | | | ពន្ធលើផលទុននៃដីធ្លី-ផ្ទះសំបែង | ៦.០០០ | ៧.០០០ | | +១.០០០ |
| | ០៨ | | | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ [២] | | | | |
| ១១ | | | | ជំពូក១១ : ពន្ធលើបេតិកភ័ណ្ឌ | | | | |
| | ០១ | | | ពន្ធប្រថាប់ត្រា[២] | | | | |
| | | ០១ | | ពន្ធផ្ទេរមតិករវាងអ្នកនៅរស់ | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ០២ | | ពន្ធផ្ទេរសទ្ធពអ្នកស្លាប | | | | |
| ១២ | | | | ជំពូក១២ : ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និង សេវា | ៣២៦.៦៨០ | ៤៦៥.០០០ | | +១៣៨.៣២០ |
| | ០១ | | | អាករលើផលរបរ : របបផ្ទៃក្នុង | ១៦.០០០ | ១២.០០០ | -៤.០០០ | |
| | | ០១ | | សហគ្រាសសាធារណៈ | | | | |
| | | | ០១ | សហគ្រាសមជ្ឈិម | | | | |
| | | | ០២ | សហគ្រាសខេត្តនានា | | | | |
| | | ០២ | | សហគ្រាសឯកជន | ១៦.០០០ | ១២.០០០ | -៤.០០០ | |
| | ០២ | | | អាករលើតំលៃបន្ថែម : របបផ្ទៃក្នុង | ៦៣.០០០ | ៧៣.០០០ | | +១០.០០០ |
| | | ០១ | | សហគ្រាសសាធារណៈ | ៣.០០០ | ៣.០០០ | | |
| | | ០២ | | សហគ្រាសឯកជន | ៦០.០០០ | ៧០.០០០ | | +១០.០០០ |
| | | | ០១ | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | | ០២ | សហគ្រាសផ្សេងៗ | | | | |
| | ០៣ | | | ពន្ធប៉ាតង់(២) | | | | |
| | ០៤ | | | អាករពិសេសលើទំនិញមួយចំនួន និង សេវាកម្ម | ៨០.០០០ | ៩៥.០០០ | | +១៥.០០០ |
| | | ០១ | | របបផ្ទៃក្នុង | ២០.០០០ | ២២.០០០ | | +២.០០០ |
| | | ០២ | | របបនៃការនាំចូល | ៦០.០០០ | ៧២.០០០ | | ១២.០០០ |
| | | | ០១ | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | | ០២ | សហគ្រាសផ្សេងៗ | | | | |
| | ០៥ | | | ពន្ធសត្តយាន(២) | | | | |
| | ០៦ | | | ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានយន្តគ្រប់ប្រភេទ(២) | | | | |
| | ០៨ | | | អាករលើតំលៃបន្ថែម : របបនាំចូល | ១៦៧.៦៨០ | ២៨៦.០០០ | | +១១៨.៣២០ |
| | | ០១ | | សហគ្រាសប្រេងឥន្ធនៈ | ៥៥.៦៨០ | ៥៦.០០០ | | +៣២០ |
| | | ០២ | | សហគ្រាសដទៃទៀត | ១១២.០០០ | ២៣០.០០០ | | +១១៨.០០០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៣ | | | | ជំពូក១៣ : ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | ៤៤០.៧០០ | ៤៩២.០០០ | | +៥១.៣០០ |
| | ០១ | | | ពន្ធ និង អាករគយពីការនាំចូល | ៤៣៣.០០០ | ៤៨០.៥០០ | | +៤៧.៥០០ |
| | | ០១ | | ពន្ធគយពីការនាំចូល | ២៣៥.០០០ | ២៩០.០០០ | | +៥៥.០០០ |
| | | ០២ | | កំរៃយកមុនលើផលិតផលប្រេងកាត | ២.០០០ | ២.៥០០ | | +៥០០ |
| | | ០៣ | | កំរៃយកមុនលើការងារគយក្នុងការនាំចូល | ៦.០០០ | ៧.០០០ | | +១.០០០ |
| | | ០៤ | | ពន្ធគយលើផលិតផលប្រេងកាត | ១៥៥.០០០ | ១៤៦.០០០ | -៩.០០០ | |
| | | ០៥ | | អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំផ្លូវថ្នល់ | ៣៥.០០០ | ៣៥.០០០ | | |
| | | ១០ | | ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចូល | | | | |
| | ០២ | | | អាករពីការនាំចេញ | ៤.៧០០ | ៨.៥០០ | | +៣.៨០០ |
| | | ០១ | | អាករគយពីការនាំចេញ | ៤.៧០០ | ៨.៥០០ | | +៣.៨០០ |
| | | | ០១ | អាករលើការនាំឈើចេញ | ២.៥០០ | ៥.០០០ | | +២.៥០០ |
| | | | ០២ | អាករលើការនាំកៅស៊ូចេញ | ១.០០០ | ២.០០០ | | +១.០០០ |
| | | | ០៣ | អាករលើការនាំផលិតផលផ្សេងៗចេញ | ១.២០០ | ១.៥០០ | | +៣០០ |
| | | ០២ | | កំរៃយកមុនលើការងារគយក្នុងការនាំចេញ | | | | |
| | | ១០ | | ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចេញ | | | | |
| | ០៣ | | | ការផាកពិន័យរបស់គយ | ៣.០០០ | ៣.០០០ | | |
| ១៤ | | | | ជំពូក១៤ : ចំណូលសារពើពន្ធផ្សេងៗទៀត | ៤.៤០០ | ៤.៤០០ | -៥០០ | |
| | ០១ | | | ពន្ធតែមប្រើ | ១.៤០០ | ១.៤០០ | | |
| | ០៤ | | | ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ | ៣.០០០ | ២.៥០០ | -៥០០ | |
| | ០៥ | | | អាករលើយានយន្តនាំចូលដោយផ្ទុយនឹងច្បាប់ | | | | |
| | ១០ | | | ចំណូលសារពើពន្ធផ្សេងៗទៀតតាមមុខពន្ធនានា | | | | |
| | | | | ប្រភេទទី២ : ចំណូលពុំមែនសារពើពន្ធ | ៣៦៦.៧២០ | ៤២០.០០០ | | +៥៣.២៨០ |
| ២០ | | | | ជំពូក២០ : ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | ១៦៩.៦៩៥ | ១៧១.៧៩០ | | +២.០៩៥ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ០១ | | | ផលនេសាទ | ១៥.០០០ | ១២.៦៨០ | -២.៣២០ | |
| | ០២ | | | ផលព្រៃឈើ | ៧៣.០០០ | ៥១.៥០០ | -២១.៥០០ | |
| | ០៣ | | | ផលទុនបានមកពីសហគ្រាសសាធារណៈ | ៤៧.៥៤០ | ៦៥.៥៧៥,៨ | | +១៧.៩៨៦ |
| | | ០១ | | ការផ្តលរោងចក្រសហគ្រាស | ៨.២១០ | ១៦.៤៨០ | | +៨.២៧០ |
| | | | ០១ | សហគ្រាសមជ្ឈឹម | ៨.២១០ | ១៦.២៨៥ | | +៨.០៧៥ |
| | | | ០២ | សហគ្រាសខេត្តនានា | | ១៩៥ | | +១៩៥ |
| | | ០២ | | ការបង់ប្រាក់រំលស់ឡើងវិញ | ២.១៩០ | ១.៨៦០ | -៣៣០ | |
| | | | ០១ | សហគ្រាសមជ្ឈឹម | ២.១៩០ | ១.៨៦០ | -៣៣០ | |
| | | | ០២ | សហគ្រាសខេត្តនានា | | | | |
| | | ០៣ | | ចំនួនលើសនៃទុនចល័ត | | | | |
| | | ០៤ | | សេវាកម្មនៃការខ្ចីចងការរបស់សហគ្រាសសាធារណៈ | | | | |
| | | ០៥ | | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | | | | |
| | | ០៦ | | ផលទុនរបស់អាកាសចរស៊ីវិល | ២៧.១០០ | ៤២.៥៦០ | | +១៥.៤៦០ |
| | | ០៧ | | ផលទុននៃសកម្មភាពភាពយន្ត | | | | |
| | | ០៨ | | ផលទុននៃសកម្មភាពទេសចរណ៍ | ៩.៨០០ | ៤.២០០ | -៥.៦០០ | |
| | | ០៩ | | ការលក់សំភារៈបរិក្ខារ | | | | |
| | | ១០ | | ការជួលសំភារៈបរិក្ខារ | | ២ | | |
| | | ១១ | | ផលនៃការដឹកជញ្ជូនទំនិញ | | ៨០,៨ | | +៨១ |
| | | ១២ | | ផលនៃប្រតិបត្តិការពាណិជ្ជកម្ម | | ៣ | | +៣ |
| | | ១៣ | | ការផ្គត់ផ្គង់អគ្គិសនីនៅតាមខេត្តនានា[២] | | | | |
| | | ១៤ | | ផលទុននៃរដ្ឋាករទឹក[២] | | | | |
| | | ២០ | | ផលទុនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈ | ២៨០ | ៣៩០ | | +១១០ |
| | ០៤ | | | កំរៃយកមុនក្នុងសម្បទានទ្រព្យសម្បត្តិរដ្ឋ | ១១.៥០០ | ១៨.៨៥៧,៥ | | +៧.៣៥៧ |
| | | ០១ | | សម្បទានពីប្រេងកាត | ៥០០ | ៥០០ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ០២ | សម្បទានពីរ៉ែ | ១.១០០ | ១.៩៩៧,៥ | | +៨៩៧ |
| | | ១០ | សម្បទានផ្សេងៗទៀត | ១០.០០០ | ១៦.៥៦០ | | +៦.៥៦០ |
| | ០៥ | | ចំណូលពីការកាន់កាប់កម្មសិទ្ធិសាធារណៈ ⁽²⁾ | | | | |
| | | ០១ | ចំណូលនៃការជួលកន្លែងលក់ដូរក្នុងទីផ្សារ | | | | |
| | | ០២ | ចំណូលពីចំណតរថយន្ត | | | | |
| | | ០៣ | ចំណូលពីកំពង់ចំលង | | | | |
| | | ០៤ | ចំណូលពីកន្លែងលក់ដោយការដេញថ្លៃ | | | | |
| | ០៦ | | ការជួលអចលនៈវត្ថុ | ២២.៥១៥ | ២២.៩៧០ | | +៤៥៥ |
| | ០៧ | | ផលពីការលក់ផ្នែកគយ | ១០០ | | -១០០ | |
| | ០៨ | | ផលបានមកពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈដើរពាសវាល ពាសកាលគ្មានម្ចាស់ និងទំនិញបោះបង់ចោល | | | | |
| | ០៩ | | ផលពីការលក់ចលនៈវត្ថុខូចខាតរបស់រដ្ឋ | | | | |
| | ២០ | | ផលផ្សេងៗទៀតពីទ្រព្យសម្បត្តិរដ្ឋ | | ២០៦,៨ | | +២០៧ |
| ២១ | | | ជំពូក២១ : ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | ១៩៧.០២៥ | ២៤៨.២១០ | | +៥១.១៨៥ |
| | ០១ | | ផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ | ១៦១.០០០ | ១៥០.២៨០ | -១០.៧២០ | |
| | ០២ | | ផលទុនវិទ្យុ ទូរទស្សន៍ ការផ្សាយ | ៤២០ | ២៨៥ | -១៣៥ | |
| | ០៣ | | ចំណូលនៃសេវាកម្មសាធារណៈ | ៣២.៨៧៥ | ៩០.៥៩២,២ | | +៥៧.៧១៧ |
| | | ០១ | កំរៃនៃការថែទាំ | ១៨ | ៤២ | | +២៤ |
| | | ០២ | ការលក់សំភារៈសិក្សា | | | | |
| | | ០៣ | អាករនៃស្ពានទូក | ១៩.៥៥០ | ២៣.៤៧០ | | +៤.១២០ |
| | | ០៤ | ផលទុននៃសកម្មភាពវប្បធម៌ | ២៩០ | ៣២០ | | +៣០ |
| | | ០៥ | ពន្ធលើអាជ្ញាប័ណ្ណនាំឈើចេញ | ២.៧០០ | ១.២០០ | -១.៥០០ | |
| | | ០៦ | ការត្រួតពិនិត្យគុណភាពផលិតផល | ៤.២០២ | ៤.៨២៨,៣ | | +៦២៦ |
| | | ០៧ | អាករលើការចុះបញ្ជីពាណិជ្ជកម្ម | ៣០០ | ៨០០ | | +៥០០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ០៨ | | ការបង់ប្រាក់ធានាសំរាប់បង្កើតសហគ្រាស | | | | |
| | | ០៩ | | ការលក់ឯកសារគយ | ២០ | | -២០ | |
| | | ១០ | | លតាប័ត្រ និង លិខិតបោះពុម្ពផ្សេងៗរបស់គយ | ១.៥០០ | ២.០០០ | | +៥០០ |
| | | ១១ | | ឯកសារផ្សេងៗទៀត | ៣.២៥៥ | ៣៥៥ | -២៩០០ | |
| | | ១២ | | ការលក់ឯកសារ និង លិខិតបោះពុម្ពរបស់ពន្ធដារ | ១០០ | ១០៨,៥ | | +៨ |
| | | ១៣ | | ផលនៃការលក់ផ្លាកលេខ | ៥០០ | ៦៣៣,៥ | | +១៣៣ |
| | | ១៤ | | ពន្ធលើការធ្វើអត្តសញ្ញាណប័ណ្ណជាតិ | | | | |
| | | ១៥ | | អាករចុះបញ្ជីគណៈបក្សនយោបាយ | | | | |
| | | ១៦ | | ចំណូលពីឆ្នោត | | ៥០ | | +៥០ |
| | | ១៧ | | ចំណូលពីកូតានាំចេញ | | ៥៦.០០០ | | +៥៦.០០០ |
| | | | ០១ | ដេញថ្លៃកូតា | | ១០.០០០ | | +១០.០០០ |
| | | | ០២ | អាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់ | | ៣៦.០០០ | | +៣៦.០០០ |
| | | ៣០ | | ចំណូលផ្សេងៗទៀតរបស់សេវាកម្មសាធារណៈ | ៥៥០ | ៦៨៥ | | +១៣៥ |
| | ០៤ | | | លំអៀងនៃអត្រាប្តូរប្រាក់ | | ៥០ | | +៥០ |
| | ០៥ | | | ចំណូលក្រៅសារពើពន្ធរបស់ខេត្តនានា | | | | |
| | ០៦ | | | ប្រាក់ចំណេញធនាគារជាតិ | | ១៥.០០០ | | +១៥.០០០ |
| | ២០ | | | ចំណូលផ្សេងៗក្រៅពីសារពើពន្ធ | ២.៧៣០ | ២.០១២,៨ | -៧១៧ | |
| | | | | **សរុបចំណូលជាមូលធន** | ២៧៥.០០០ | ៨៧០.០០០ | | +៥៩៥.០០០ |
| | | | | **ប្រភេទទី៣ : ចំណូលជាមូលធន** | ២៧៥.០០០ | ៨៧០.០០០ | | +៥៩៥.០០០ |
| ៣០ | | | | ជំពូក៣០ : ចំណូលផ្ទៃក្នុងជាមូលធន | ២៥.០០០ | ២០.០០០ | -៥.០០០ | |
| | ០១ | | | ការលក់ទ្រព្យសម្បត្តិនៃមូលធនថេរ | | | | |
| | ០២ | | | ការលក់ដីធ្លី | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ០៣ | | | ការលក់ទ្រព្យសកម្មអរូបិយ និង ហិរញ្ញវត្ថុ | | | | |
| | ០៤ | | | ផលឯកជនភាវូបនីយកម្ម | ២៥.០០០ | ២០.០០០ | -៥.០០០ | |
| | ១៥ | | | ចំណូលពីការខ្ចីបុលក្នុងប្រទេស | | | | |
| ៣១ | | | | ជំពូក៣១ : អំណោយពីបរទេស | ៥០.០០០ | ៥០០.០០០ | | +៣៥០.០០០ |
| | ០១ | | | ជំនួយមនុស្សធម៌ | | | | |
| | | ០១ | | ........................................ | | | | |
| | ០២ | | | មូលនិធិបដិភាគ | ៥០.០០០ | | -៥០.០០០ | |
| | | ០១ | | ជប៉ុន | | | | |
| | | ០២ | | អាល្លឺម៉ង់ | | | | |
| | | ០៣ | | បែលហ្ស៊ិក | | | | |
| | | ០៤ | | ចក្រភពអង់គ្លេស | | | | |
| | | ០៥ | | បារាំង | | | | |
| | | ០៦ | | អង្គការសហប្រជាជាតិ | | | | |
| | | ០៧ | | អ៊ីតាលី | | | | |
| | | ០៨ | | ស៊ុយអែដ | | | | |
| | | ៣០ | | ផ្សេងៗទៀត | | | | |
| | ០៣ | | | អំណោយផ្សេងៗទៀតពីបរទេស | | ៥០០.០០០ | | +៥០០.០០០ |
| | | ០១ | | ជប៉ុន | | | | |
| | | ០២ | | សហរដ្ឋអាមេរិក | | | | |
| | | ០៣ | | អង្គការសហប្រជាជាតិ | | | | |
| | | ០៤ | | បារាំង | | | | |
| | | ០៥ | | អូស្ត្រាលី | | | | |
| | | ៣០ | | ផ្សេងៗទៀត | | | | |
| | ០៤ | | | អំណោយដោយឡែកសំរាប់រំលស់បំណុល | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣២ | | | | ជំពូក៣២ : ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីប្រាក់ | ២០០.០០០ | ៤៥០.០០០ | | +២៥០.០០០ |
| | ០១ | | | ប្រភពទុនខ្ចីផ្ទៃក្នុង | | | | |
| | | ០១ | | ប្រភពទុនខ្ចីផ្ទៃក្នុងបានមកពីប្រព័ន្ធធនាគារ | | | | |
| | | | ០១ | ........................................ | | | | |
| | | ០២ | | ប្រភពទុនខ្ចីផ្ទៃក្នុងផ្សេងៗទៀត | | | | |
| | | | ០១ | ........................................ | | | | |
| | ០២ | | | ប្រភពទុនខ្ចីពីបរទេស | ២០០.០០០ | ៤៥០.០០០ | | +២៥០.០០០ |
| | | ០១ | | ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា | ២០០.០០០ | ៤៥០.០០០ | | +២៥០.០០០ |
| | | | ០១ | ធនាគារពិភពលោក | ៩០.០០០ | ២៥០.០០ | | +១៦០.០០០ |
| | | | | មូលនិធិឧបត្ថម្ភ | | ១៥០.០០០ | | +១៥០.០០០ |
| | | | | ឥណទានខ្ចី | ៩០.០០០ | ១០០.០០០ | | +១០.០០០ |
| | | | ០២ | ធនាគារអាស៊ីសម្រាប់អភិវឌ្ឍន៍ | ១១០.០០០ | ២០០.០០០ | | +៩០.០០០ |
| | | | | មូលនិធិឧបត្ថម្ភ | | | | |
| | | | | ឥណទានខ្ចី | ១១០.០០០ | ២០០.០០០ | | +៩០.០០០ |
| | | | ០៣ | ................................ | | | | |
| | | ០២ | | ប្រភពទុនខ្ចីពីបរទេសបានមកពីរដ្ឋាភិបាល និង អង្គការទំនាក់ទំនង | | | | |
| | | | ០១ | ............................ | | | | |
| | | ០៣ | | ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការឯកជននានា | | | | |
| | | | ០១ | ............................ | | | | |

[២] ចំណូលសារពើពន្ធ និង ពុំមែនសារពើពន្ធ ដែលបានផ្ទេរឲ្យថវិកាខេត្ត-ក្រុង ដោយអនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាង "ខ"

## ចំណាយថវិកាថ្នាក់កណ្តាលរបស់រដ្ឋ

ការបូកសរុបចំណាយតាមក្រសួង និង តាមប្រភេទ

ឯកតា : លានរៀល

| ប្រភេទ / ក្រសួងនានា | សរុបរួម នៃចំណាយ | សរុប ចំណាយជាប្រចាំ | ប្រភេទទី១ មធ្យោបាយសេវា | ប្រភេទទី២ ការប្រាក់នៃការខ្ចីបុល | ប្រភេទទី៣ អន្តរាគមន៍សាធារណៈ | ប្រភេទទី៤ ចំណាយផ្សេងៗ និង ចំ.មិនបានគ្រោងទុក | ប្រភេទទី៥ សរុបចំណាយជាមូលធន |
|---|---|---|---|---|---|---|---|
| សរុបរួមចំណាយ | ២.៣៥៥.០០០,០ | ១.៣១៥.០០០,០ | ១.០៣១.៩៥០,០ | ២៥.០០០,០ | ១៧៧.០៥០,០ | ៨១.០០០,០ | ១.០៤០.០០០,០ |
| សរុបរដ្ឋបាលកណ្តាល | ២.០៥៩.១២០,០ | ១.០១៩.១២០,០ | ៨១៩.៨៣០,០ | ២៥.០០០,០ | ៩៣.២៩០,០ | ៨១.០០០,០ | ១.០៤០.០០០,០ |
| សរុបខេត្ត-ក្រុង | ២៩៥.៨៨០,០ | ២៩៥.៨៨០,០ | ២១២.១២០,០ | | ៨៣.៧៦០,០ | | |
| ០១. ព្រះបរមរាជវាំង | ១៨.៥០០,០ | ១៨.៥០០,០ | ៩.៣០០,០ | | ៩.២០០,០ | | |
| ០២. រដ្ឋសភា | ១៨.០០០,០ | ១៨.០០០,០ | ១៦.១៧៥,០ | | ១.៨២៥,០ | | |
| ០៣. ព្រឹទ្ធសភា | ៩.០០០,០ | ៩.០០០,០ | ៨.៥៥៥,០ | | ៤៤៥,០ | | |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | ១.៩៥០,០ | ១.៩៥០,០ | ១.៩១៥,០ | | ៣៥,០ | | |
| ០៥. គណៈរដ្ឋមន្ត្រី | ៤០.៣៦៥,០ | ៤០.៣៦៥,០ | ៣៥.៧៣០,០ | | ៤.៦៣៥,០ | | |
| ១-ទីស្តីការគណៈរដ្ឋមន្ត្រី | ៣៣.៥៥០,០ | ៣៣.៥៥០,០ | ២៩.១៤០,០ | | ៤.៤១០,០ | | |
| ២-រដ្ឋ.ដ្ឋានមុខងារសាធារណៈ | ៥៩៥,០ | ៥៩៥,០ | ៥៩០,០ | | ៥,០ | | |
| ៣-រដ្ឋ.ដ្ឋានអាកាសចរស៊ីវិល | ៤.០០០,០ | ៤.០០០,០ | ៣.៨០០,០ | | ២០០,០ | | |
| ៤-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ២.២២០,០ | ២.២២០,០ | ២.២០០,០ | | ២០,០ | | |
| ០៦. ក្រសួងការពារជាតិ | ៣១១.២០០,០ | ៣១១.២០០,០ | ២៩៦.៦០០,០ | | ១៤.៦០០,០ | | |
| ០៧. ក្រសួងមហាផ្ទៃ | ១៩២.៧០០,០ | ១៩២.៧០០,០ | ១៨៩.៦៥០,០ | | ៣.០៥០,០ | | |
| ១-សន្តិសុខសាធារណៈ | ១៩៣.៨០០,០ | ១៩៣.៨០០,០ | ១៩១.៦៥០,០ | | ២.១៥០,០ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២-រដ្ឋបាលទូទៅ | ៨.៩០០,០ | ៨.៩០០,០ | ៨.០០០,០ | | ៩០០,០ | | |
| ៩-ខេត្ត-ក្រុងនានា | | | | | | | |
| ០៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធ-សភា និងអធិការកិច្ច | ១.០១០,០ | ១.០១០,០ | ៩៩០,០ | | ២០,០ | | |
| ០៩. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ៤៩.៩៦០,០ | ៤៩.៩៦០,០ | ៣៧.៦៦០,០ | | ១២.២០០,០ | | |
| ១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៣១.១២០,០ | ៣១.១២០,០ | ៣០.៥១៩,០ | | ៦០១,០ | | |
| ១-ក្រសួង | ២៩.១២០,០ | ២៩.១២០,០ | ២៨.៦២០,០ | | ៥០០,០ | | |
| ៩-ខេត្ត-ក្រុងនានា | ២.០០០,០ | ២.០០០,០ | ១.៨៩៩,០ | | ១០១,០ | | |
| ១១. ក្រសួងព័ត៌មាន | ៥.៤០០,០ | ៥.៤០០,០ | ៥.៩១០,០ | | ៩០,០ | | |
| ១-ក្រសួង | ៣.៤០០,០ | ៣.៤០០,០ | ៣.៩៦៥,០ | | ៣៥,០ | | |
| ៩-ខេត្ត-ក្រុងនានា | ២.០០០,០ | ២.០០០,០ | ១.៩៤៥,០ | | ៥៥,០ | | |
| ១២. ក្រសួងសុខាភិបាល | ១២១.០០០,០ | ១២១.០០០,០ | ១១៩.៣២៦,០ | | ១.៦៧៤,០ | | |
| ១-ក្រសួង | ៨១.០០០,០ | ៨១.០០០,០ | ៨០.១០០,០ | | ៩០០,០ | | |
| ៩-ខេត្ត-ក្រុងនានា | ៤០.០០០,០ | ៤០.០០០,០ | ៣៩.២២៦,០ | | ៧៧៤,០ | | |
| ១៣. ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល | ៦.០៦០,០ | ៦.០៦០,០ | ៤.៧៤៣,០ | | ១.៣១៧,០ | | |
| ១-ក្រសួង | ៣.១៦០,០ | ៣.១៦០,០ | ២.៥៨០,០ | | ៥៨០,០ | | |
| ៩-ខេត្ត-ក្រុងនានា | ២.៩០០,០ | ២.៩០០,០ | ២.១៦៣,០ | | ៧៣៧,០ | | |
| ១៤. ក្រសួងផែនការ | ៣.៤៦០,០ | ៣.៤៦០,០ | ៣.៣៦៨,០ | | ៩២,០ | | |
| ១-ក្រសួង | ១.៧០០,០ | ១.៧០០,០ | ១.៦៦០,០ | | ៤០,០ | | |
| ៩-ខេត្ត-ក្រុងនានា | ១.៧៦០,០ | ១.៧៦០,០ | ១.៧០៨,០ | | ៥២,០ | | |
| ១៥. ក្រសួងពាណិជ្ជកម្ម | ៧.០៧០,០ | ៧.០៧០,០ | ៥.៩៤៤,០ | | ១.១២៦,០ | | |
| ១-ក្រសួង | ៥.១៧០,០ | ៥.១៧០,០ | ៤.១៥០,០ | | ១.០២០,០ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩-ខេត្ត-ក្រុងនានា | ១.៩០០,០ | ១.៩០០,០ | ១.៧៩៥,០ | | ១០៦,០ | | |
| ១៦. ក្រសួងអប់រំ យុវជន និងកីឡា | ១៨៣.១៧០,០ | ១៨៣.១៧០,០ | ១៧៦.៥៦០,០ | | ៦.៦១០,០ | | |
| ១-អប់រំ | ៣៥.៣២០,០ | ៣៥.៣២០,០ | ៣៤.៨០០,០ | | ៥២០,០ | | |
| ២-ឧត្តមសិក្សា | ១១.២៨០,០ | ១១.២៨០,០ | ១០.២៧០,០ | | ១.០១០,០ | | |
| ៣-យុវជន និង កីឡា | ៧.២៨០,០ | ៧.២៨០,០ | ៦.៣០០,០ | | ៩៨០,០ | | |
| ៩-ខេត្ត-ក្រុងនានា | ១២៩.២៩០,០ | ១២៩.២៩០,០ | ១២៥.១៩០,០ | | ៤.១០០,០ | | |
| ១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២៦.០១០,០ | ២៦.០១០,០ | ២១.៣៧១,០ | | ៤.៦៣៩,០ | | |
| ១-ក្រសួង | ១៥.៦០០,០ | ១៥.៦០០,០ | ១២.៦៥០,០ | | ១.៩៥០,០ | | |
| ៩-ខេត្ត-ក្រុងនានា | ១១.៤១០,០ | ១១.៤១០,០ | ៨.៧២១,០ | | ២.៦៨៩,០ | | |
| ១៨. ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ៧.៥០០,០ | ៧.៥០០,០ | ៧.០៨៤,០ | | ៤១៦,០ | | |
| ១-ក្រសួង | ៤.៧០០,០ | ៤.៧០០,០ | ៤.៤២០,០ | | ២៨០,០ | | |
| ៩-ខេត្ត-ក្រុងនានា | ២.៨០០,០ | ២.៨០០,០ | ២.៦៦៤.០ | | ១៣៦.០ | | |
| ១៩. ក្រសួងបរិស្ថាន | ៥.០០០,០ | ៥.០០០,០ | ៣.៨៦៨,០ | | ១៣២,០ | | |
| ១-ក្រសួង | ២.៦០០,០ | ២.៦០០,០ | ២.៥១០,០ | | ៩០,០ | | |
| ៩-ខេត្ត-ក្រុងនានា | ១.៥០០.០ | ១.៥០០,០ | ១.៣៥៨.០ | | ៤២,០ | | |
